# សកលវិទ្យាល័យនៃរដ្ឋកាលីហ្វ័រញ៉ា ទីក្រុង IRVINE
## សិទ្ធិរបស់បុគ្គលដែលចូលរួមការពិសោធ

សិទ្ធិដែលបានរៀបរាប់ខាងក្រោមនេះ គឺជាសិទ្ធិរបស់បុគ្គលទាំងអស់ដែលត្រូវបានស្នើសុំឱ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ អ្នកមានសិទ្ធិះ

១. ទទួលបានដំណឹងអំពីលក្ខណៈ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ។

២. ទទួលបានដំណឹងអំពីទម្រង់ការ ដែលត្រូវធ្វើតាមក្នុងកិច្ចសិក្សាស្រាវជ្រាវ ហើយត្រូវបានដឹងថាតើឱសថ ឧបករណ៍ ឬក៏ទម្រងការមានការខុសប្លែកពីអ្វីដែលគេប្រើប្រាស់ជាទូទៅដែរទេ។

៣. ទទួលបានដំណឹងអំពីផលប៉ះពាល់ ភាពមិនស្រួលខ្លួន ឬក៏ហានិភ័យណាមួយដែលអាចគ្រោងទុកជាមុនថាប្រហែលនឹងអាចកើតមានឡើងក្នុងអំឡុងពេលធ្វើការសិក្សាស្រាវជ្រាវនេះ។

៤.ទទួលបានដំណឹងអំពីផលប្រយោជន៍ណាមួយដែលអាចគួរទួទួលបានពីការចូលរួមក្នុងកិច្ចសិក្សាស្រាវជ្រាវនេះ ប្រសិនបើមាន។

៥. ទទួលបានដំណឹងអំពីទម្រង់ការផ្សេងទៀត ឱសថផ្សេងទៀត ឬក៏ឧបករណ៍ផ្សេងទៀតដែលអាចជួយបានប្រសើជាង បើប្រៀបធៀបផលប៉ះពាល់ទៅនឹងផលប្រយោជន៍នៃទម្រង់ការ ឱសថ ឬក៏ឧបករណ៍ដែលបានគ្រោងទុកប្រើពីខាងដើម។

៦. ទទួលបានដំណឹងអំពីប្រភេទនៃការព្យាបាល ប្រសិនបើមាន ក្នុងករណីមានការហាកជម្ងឺ (កើតមានភាពស្មុគ្រស្មាញ)។

៧. ទទួលបានឳកាសដើម្បីសួរសំនួរទាក់ទងនឹងការសិក្សាស្រាវជ្រាវនេះ ទាំងនៅពេលមុនស្ម័គ្រចិត្តចូលរួម និងនៅក្នុងអំឡុងពេលដែលកិច្ចសិក្សាស្រាវជ្រាវនេះកំពុងតែប្រព្រឹត្តទៅ។

៨. បដិសេធមិនចូលរួមក្នុងកិច្ចសិក្សាស្រាវជ្រាវ។ ការចូលរួមគឺធ្វើឡើងដោយស្ម័គ្រចិត្ត។ អ្នកអាចបដិសេធមិនឆ្លើយនឹងសំនួរណាមួយ ឬក៏ឈប់បន្តការជាប់ពាក់ព័ន្ធរបស់អ្នកក្នុងកិច្ចសិក្សាស្រាវជ្រាវនេះ ដោយមិនមានទទួលការពិន័យ ឬក៏បាត់បង់ផលប្រយោជន៍ណាមួយដែលអ្នកមានសិទ្ធិទទួលបានទេ។ ការសម្រេចចិត្តរបស់អ្នកនឹងមិនប៉ះពាល់ដល់សិទ្ធិដែលអ្នកមានក្នុងការទទួលការមើលថែទាំដូចជាពេលដែលអ្នកមិនបានចូលរួមក្នុងកិច្ចសិក្សាស្រាវជ្រាវនេះដែរ។

៩. ទទួលបានលិខិតយល់ព្រមចូលរួមមួយច្បាប់ ដែលមានចុះហត្ថលេខារួចហើយ និងទម្រង់នេះមួយច្បាប់ដែរ។

Version: January 2011

១០. ទទួលបានឱកាសដើម្បីធ្វើការសម្រេចចិត្តដោយសេរី ថាតើគួរឬមិនគួរចូលរួមក្នុងកិច្ចសិក្សាស្រាវជ្រាវមួយនេះ ដោយគ្មានការបង្ខិតបង្ខំ ឬក៏ប្រើប្រាស់ឥទ្ធិពលអូសទាញហួសហេតុ។

---

ប្រសិនបើអ្នកមានសំនួរ ឬក៏ការព្រួយបារម្ភអ្វីមួយពាក់ព័ន្ធនឹងកិច្ចសិក្សាស្រាវជ្រាវនេះ អ្នកគួរទាក់ទងទៅក្រុមស្រាវជ្រាវដែលបានកត់ត្រានៅខាងលើនៃលិខិតយល់ព្រម។

ប្រសិនបើអ្នកទាក់ទងទៅមិនបានជួបជាមួយសមាជិកក្រុមស្រាវជ្រាវណាម្នាក់ទេនោះ ហើយសំនួរដែលអ្នកមាន គឺជាសំនួរទូទៅ ឬក៏អ្នកមានការព្រួយបារម្ភ ឬក៏បណ្តឹងពាក់ព័ន្ធនឹងកិច្ចសិក្សាស្រាវជ្រាវនេះ ឬក៏ក្រុមស្រាវជ្រាវ ឬក៏សំនួរស្តីអំពីសិទ្ធិរបស់អ្នកក្នុងនាមជាអ្នកគេយកទៅធ្វើពិសោធ សូមអ្នកទាក់ទងមក UCI's Human Research Protections Program នៅក្នុង Office of Research តាមទូរសព្ទលេខ (៩៤៩) ៨២៤ ៦០៦៨ ឬ (៩៤៩) ៨២៤ ២១២៥ ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ចាប់ពីម៉ោង ៨ព្រឹក ដល់ ៥ល្ងាច ឬ តាមអ៊ីម៉ែល IRB@research.uci.edu; ឬ តាមការសរសេរសំបុត្រ ផ្ញើមកអស័យដ្ឋាន 5171 California, Suite 150, Irvine, CA 92697-7600។